UNITED NATIONS
HUMAN RIGHTS
SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# សេចក្តីថ្លែងការណ៍ដាក់បញ្ជូនដោយសាស្ត្រាចារ្យ រ៉ូណាស្មីត អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាព សិទ្ធិមនុស្សនៅកម្ពុជា សម្រាប់ជំនួបប្រជុំ ដែលបានរៀបចំឡើងដោយសហរដ្ឋអាមេរិក/សហភាពអឺរ៉ុប នៅទីក្រុងញូវយ៉ក ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧

សូមអរគុណចំពោះការអញ្ជើញចូលរួមក្នុងជំនួបប្រជុំនេះ។ បច្ចុប្បន្នខ្ញុំមិនស្ថិតនៅទីក្រុងញូវយ៉កទេ ដូច្នេះ ខ្ញុំដាក់ បញ្ជូនសេចក្តីថ្លែងការណ៍នេះ ស្តីពីស្ថានភាពនយោបាយបច្ចុប្បន្ននៅកម្ពុជា។

ឆ្នាំ២០១៧ បាននាំមកនូវបញ្ហាប្រឈមជាច្រើន សម្រាប់អ្នកការពារសិទ្ធិមនុស្ស និងអ្នកនយោបាយនៅក្នុងប្រទេសកម្ពុជា បើទោះជាមានចំណុចជោគជ័យមួយចំនួនក្តី។ សម្រាប់ទិដ្ឋភាពវិជ្ជមាន ក្នុងខែតុលា សមាជិកព្រឹទ្ធសភា លោក ហុង សុខហួរ បានទទួលការលើកលែងទោសពីព្រះមហាក្សត្រ ហើយត្រូវបានដោះលែងពីពន្ធនាគារ។ ខ្ញុំក៏កត់សម្គាល់ផងដែរថា លោក នី ចរិយា អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានដោះលែងពីការឃុំខ្លួនជាបណ្តោះអាសន្ន កាលពីខែមិថុនា បន្ទាប់ពីបានជាប់ឃុំរយៈពេល ៤២៧ ថ្ងៃ ប៉ុន្តែលោកនៅតែស្ថិតក្រោមការឃ្លាំមើលតាមផ្លូវតុលាការនៅឡើយ ដោយព្យួរការចោទប្រកាន់។

នៅថ្ងៃទី៤ ខែមិថុនា ការបោះឆ្នោតឃុំ-សង្កាត់ ត្រូវបានធ្វើឡើងដោយមានសណ្តាប់ធ្នាប់ និងសន្តិវិធីគួរសមដែរ។ ឃើញមានអ្នកចេញទៅបោះឆ្នោតក្នុងអត្រាខ្ពស់។ អ្នកអត្ថាធិប្បាយជាច្រើន រួមទាំងអ្នកដែលមានវត្តមាននៅថ្ងៃនេះ បានសម្តែងការមិនពេញចិត្តចំពោះបរិយាកាសទូទៅនៅមុខពេល ហើយជាពិសេសគឺនៅក្រោយពេលបោះឆ្នោត។ កង្វល់បែបនេះ ត្រូវបានបង្ហាញយ៉ាងច្បាស់ មិនត្រឹមតែប៉ុណ្ណោះមានករណីនៃការគំរាមកំហែង សេចក្តីថ្លែងការណ៍មានលក្ខណៈវាយប្រហារ និងការបំភិតបំភ័យពីតួអង្គនយោបាយនយោបាយជាន់ខ្ពស់ផងដែរ។

ខ្ញុំនៅតែកង្វល់អំពីការរំលាយគណៈបក្សសង្គ្រោះជាតិ (CNRP) កាលពីថ្ងៃទី ១៦ ខែវិច្ឆិកា ការហាមឃាត់សមាជិកគណៈបក្សសង្គ្រោះជាតិចំនួន ១១៨ រូប មិនឲ្យធ្វើសកម្មភាពនយោបាយក្នុងរយៈពេលប្រាំឆ្នាំ ហើយនិងការបែងចែកអាសនៈជាប់ឆ្នោតទាំងអស់របស់គណៈបក្សនេះទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទៅឲ្យសមាជិកទាំងឡាយរបស់គណបក្សកាន់អំណាច និងគណបក្សផ្សេងទៀតដែលមិនត្រូវបានប្រជាជនបោះឆ្នោតឲ្យ៉។ ទោះបីជាខ្ញុំដឹងអំពីច្បាប់ដែលបានអនុម័តយ៉ាងឆាប់រហ័សស្តីពីការបែងចែកអាសនៈឡើងវិញក៏ដោយ ក៏ការអនុវត្តច្បាប់នោះ បានបដិសេធសិទ្ធិមួយផ្នែកធំរបស់ប្រជាពលរដ្ឋក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ តាមរយៈតំណាងដែលពួកគេបានជ្រើសរើសដោយសេរី។ តាមពិតទៅ ប្រជាពលរដ្ឋបោះឆ្នោតឲ្យតំណាងរបស់ CNRP នៅក្នុងរដ្ឋសភាជាតិធ្វើជាតំណាងរបស់ខ្លួនទេ តែបែរជាយកភាពជាតំណាងទាំងនេះបែងចែកឲ្យទៅគណបក្សមួយផ្សេងទៀតទៅវិញ។ ប្រជាពលរដ្ឋដែលបានបោះឆ្នោតឲ្យ CNRP ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ នៅថ្ងៃទី៤ ខែមិថុនា ក៏សង្កេតឃើញថាមន្ត្រីដែលខ្លួនបោះឆ្នោតឲ្យត្រូវបានប្តូរដាក់អ្នកថ្មីផងដែរ។ នោះក៏នឹងមានផលប៉ះពាល់ដល់ការសម្រេចចិត្តនាពេលខាងមុខនេះស្តីពីការជ្រើសតាំងព្រឹទ្ធសភា។

សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ និងសេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិមនុស្ស ដែលត្រូវបានអនុម័តកាលពីជាងប្រាំឆ្នាំមុន នៅរាជធានីភ្នំពេញ ធានានូវសិទ្ធិចូលរួមក្នុងរដ្ឋាភិបាល តាមរយៈការបោះឆ្នោតពិតប្រាកដ ដោយសេរី និងយុត្តិធម៌។ រដ្ឋធម្មនុញ្ញកម្ពុជាក៏មានចែងដូចគ្នានេះដែរ។ ការរឹតត្បិតសំឡេងរបស់ប្រជាពលរដ្ឋកម្ពុជា នៅទីបញ្ចប់ អាចគំរាមកំហែងដល់ស្ថេរភាព ដែលរដ្ឋាភិបាលគួសបញ្ជាក់ជាទៀតទាត់ និងស្ថេរភាពដែលរដ្ឋាភិបាល ប្រជាជនកម្ពុជា និងមនុស្សជាច្រើនទៀតបានធ្វើការដើម្បីការពារ។

មុនការរំលាយគណៈបក្សសង្គ្រោះជាតិ (CNRP) ប្រធានគណបក្សនេះ លោក គឹម សុខា ត្រូវបានឃុំខ្លួនកាលពីខែកញ្ញា (តែប៉ុន្មានថ្ងៃក្រោយពីបេសកកម្មចុងក្រោយរបស់ខ្ញុំនៅកម្ពុជា) ពីបទសន្និដ្ឋិភាពជាមួយបរទេស ដែលជាទង្វើមួយសំដៅដល់ "ការបង្កអរិភាព ឬសកម្មភាព ឈ្លានពានប្រឆាំងនឹងកម្ពុជា"។ រដ្ឋាភិបាលបានពន្យល់ជាសាធារណៈថា សន្និដ្ឋិភាពនេះ កើតចេញពីសុន្ទរកថាមួយ នៅប្រទេសអូស្ត្រាលី កាលពីឆ្នាំ ២០១៣ ដែលអាចរកបានតាមអនឡាញ។ បើទោះជាយ៉ាងនេះក៏ដោយ គេអះអាងថាលោកត្រូវបានចាប់ខ្លួនពី*បទល្មើសជាក់ស្តែង* ទៅវិញ ដែលធ្វើដូច្នេះ ដើម្បីបញ្ចៀសដំណើរការនីតិវិធីធម្មតាក្នុងការដកអភ័យឯកសិទ្ធិសភា។ មុនពេលចោទប្រកាន់ លោកក៏ត្រូវបានបដិសេធផងដែរនូវសិទ្ធិស្របច្បាប់ជាច្រើនដែលមានចែងក្នុងច្បាប់កម្ពុជា រាប់ទាំង សិទ្ធិប្រាស្រ័យទាក់ទងជាសម្ងាត់ជាមួយមេធាវីរបស់លោក និងវត្តមានមេធាវីនៅក្នុងអំឡុងពេលសាកសួរដោយចៅក្រមស៊ើបអង្កេត។

វាពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សហគមន៍អន្តរជាតិ និងតួអង្គសង្គមស៊ីវិលដើម្បីឃ្លាំមើលស្ថានភាពនៅកម្ពុជា និងដើម្បីលើកឡើងនូវកង្វល់នានាជាសាធារណៈ និងជាលលក្ខណៈឯកជនជាមួយរដ្ឋាភិបាល។ មានវេទិកាផ្សេងគ្នាជាច្រើនបើកចំហសម្រាប់ការលើកឡើងនូវកង្វល់ទាំងនោះ។ ខ្ញុំបន្តប្រើប្រាស់ឱកាសដែលផ្តល់តាមរយៈអាណត្តិរបស់ខ្ញុំក្នុងការតស៊ូមតិ ឃ្លាំមើល និងរាយការណ៍ ដើម្បីជួយរដ្ឋាភិបាលធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។